# ការសំភាសន៍របស់បងស្រី ជឿន ណាក់

កៈ អ្នកដែរសំភាសន៍ ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ ជឿន ណាក់

## ការសង្ខេបប្រវត្តិរបស់ បងស្រី ជឿន ណាក់

បងស្រី ជឿន ណាក់ មានអាយុ35ឆ្នាំនៅក្នុងឆ្នាំ2018 បងស្រី ជឿន ណាក់ មានភេទស្រី បងស្រី ជឿន ណាក់ មានទីលំនៅបច្ចុប្បន្ននៅ ភូមិស្ទឹងជ្រៅ ឃុំផ្សារដើមមាន ក្រុងតាខ្មៅ ខេត្តកណ្តាល។

កៈ
ចឹងជាដំបូងខ្ញុំអរគុណបងដែរបានអោយខ្ញុំពិភាក្សាជាមួយបងដែរទាក់ទងពីប្រវត្តិរបស់បង ហើយការពិភាក្សាមួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរ មានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់
បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹង
ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍បង
ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមាន ឈ្មោះថា www.cambodianoralhistories.byu.edu
ចឹងសំរាប់បងស្រីយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍
មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេបង
បងយ់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍បងនឹងទៅក្នុងវេបសាយរបស់សាលាដើម្បីទុក អោយកូនចៅ របស់បងដែរទេបង?

ខៈ ចា៎!!យល់ព្រម

កៈ បាទបងបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍បងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ
ហើយថ្ងៃខែដែរ ខ្ញុំបានសំភាសន៍បងគឺនៅថ្ងៃទី6ខែ4 ឆ្នាំ2018
ហើយការសំភាសន៍ទាំងអស់នឹងធ្វើនៅភូមិអីគេដែរបងនៅនឹង?

ខៈ ភូមិស្ទឹងជ្រៅ

កៈ ភូមិស្ទឹងជ្រៅ ចុះស្រុកវិញបង?

ខៈ នៅស្រុកដើមមាន

កៈ នៅស្រុកដើមមាន ចុះឃុំវិញបង?

ខៈ ស្រុកដើមមាន ឃុំដើមមានដែរនឹង

កៈ ចុះឃុំអីគេដែរទៅបង?

ខៈ ឃុំដើមមានដែរនឹងហាស

កៈ ឃុំដើមមានដែរចឹងតែម្តងហោសបង នៅខេត្តកណ្តាល?

ខៈ ចា៎!!នៅស្រុកស្អាង ខេត្តកណ្តាលនឹងហាស

កៈ នៅក្រុងតាខ្មៅហីបង ខេត្តកណ្តាលហីបង?

ខៈ អានឹងគេយកចឹងទាំងអស់នឹងមែន?

កៈ បាទដោយសារតែគេថាអានឹងនៅក្រុងតាខ្មៅនឹង?

ខៈ ត្រូវហើយអានឹងត្រូវហើយនឹងក្រុងតាខ្មៅនឹងហើយ
ចឹងអានឹងគេយកចឹងទាំងអស់ដែរហោស?

កៈ បាទបង ចុះបងសួរខ្ញុំនឹងខ្ញុំនៅនៅកន្លែងផ្សេងនឹង?

ខៈ ខ្លាចថាខ្ញុំឆ្លើយថាខុសហាស

កៈ អត់អីទេបងអត់អីទេនឹង?

ខៈ ខ្ញុំខ្លាចឆ្លើយថាខេត្តកណ្តាលទៅខ្លាចថាវាខុសហាស

កៈ អត់អីទេបងអត់អីទេពីព្រោះថានៅនឹងសុទ្ធតែខេត្តកណ្តាលនឹងហើយបង?

ខៈ នឹងហើយនៅក្រុងតាខ្មៅនៅខេត្តកណ្តាលនឹងហាស

កៈ បាទបងចុះសំរាប់ចឹងឈ្មោះពេញរបស់បងនឹងមានឈ្មោះអីគេដែរទៅបង?

ខៈ ខ្ញុំមានឈ្មោះជឿន ណាក់

កៈ បងឈ្មោះជឿន ណាក់ ចុះមានឈ្មោះហៅក្រៅដែរទេបង?

ខៈ ខ្ញុំមានដែរតើនឹង

កៈ ចុះមានឈ្មោះអីគេដែរទៅបង?

ខៈ ឈ្មោះហៅក្រៅរបស់ខ្ញុំនឹងគេហៅតែងឺតៗៗនឹង

កៈ ហៅឈ្មោះងឺត
ចុះកាលពីក្មេងនៅប៉ុនៗៗនេះហាសធ្លាប់មាននរណាហៅឈ្មោះបងអីផ្សេងទៀតទេបង?

ខៈ អត់ទេមានតែប៉ុណ្ណឹងឈ្មោះអើយណាក់ចឹង

កៈ អូ៎!!បាទបងបាទ?

ខៈ ដល់ពេលឥឡូវនឹងគេដូរឈ្មោះហាសដោយសារតែយើងប៉ុនឈឺពេកហាស

កៈ បាទបងចុះបងសព្វថ្ងៃនឹងបងអាយុប៉ុន្មានដែរបង?

ខៈ ខ្ញុំអាយុ35ឆ្នាំហើយនឹង

កៈ បងអាយុ35ឆ្នាំ ចុះបងកើតនៅថ្ងៃខែឆ្នាំណាដែរបងមានចងចាំទេ?

ខៈ ខ្ញុំអត់ចងចាំផងពីព្រោះអីយូរដែរហើយនឹង

កៈ ប៉ុន្តែឆ្នាំវិញបងមានដឹងថាឆ្នាំប៉ុន្មានដែរទេ?

ខៈ ខ្ញុំហោសខ្ញុំដឹងតែឆ្នាំមមែ

កៈ ចឹងបងឆ្នាំមមែ ប៉ុន្តែបង?

ខៈ ចា៎!!ដោយសារតែយើងអត់មានចងចាំថ្ងៃចងចាំខែផងនឹងវាយូរដែរហើយនឹង

កៈ បាទបង ចុះឆ្នាំវិញបងមានដឹងថានៅឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានដែរទេ?

ខៈ ដូចជានៅក្នុងឆ្នាំ1998ហី

កៈ អូ៎!!មិនមែនទេបងនៅក្នុងឆ្នាំ1983ទេបង?

ខៈ នៅក្នុងឆ្នាំ1983ហោស

ក៖  បាទបងបាទនៅឆ្នាំ1983នឹងហើយ?

ខ៖  ពីព្រោះអីខ្ញុំកើតមកនឹងគេបែកហើយនឹងហាស

ក៖  ចឹងសំរាប់បងកើតនៅណាដែរបងទីកន្លែងកំណើតរបស់បងហាស?

ខ៖  ខ្ញុំកើតនៅត្នោតញីនឹង នៅស្រុកស្អាងខេត្តកណ្ដាលនឹង ខ្ញុំនៅត្នោតញីខ្ញុំទើបតែមកនៅនឹង

ក៖  ចឹងបងនៅត្នោតញីណាបង?

ខ៖  ចា៎!!នឹងហើយចឹង

ក៖  ចុះប៉ុន្តែនៅភូមិអីគេដែរទៅបង?

ខ៖  នៅក្នុងភូមិខ្ពក

ក៖  នៅភូមិខ្ពក ចុះឃុំវិញបង?

ខ៖  នៅឃុំតាលុន

ក៖  ចឹងនៅឃុំតាលុន នៅស្រុកស្អាងខេត្តកណ្ដាល?

ខ៖  ចា៎!!នឹងហើយចឹង

ក៖  ចុះបងមានបងប្អូនចំនួនប៉ុន្មាននាក់ដែរទៅបង?

ខ៖  ខ្ញុំមានបងប្អូនចំនួន8នាក់នឹង

ក៖  ចុះចឹងមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរទៅបង?

ខ៖  មានស្រី5នាក់នឹង ប្រុស3នាក់នឹង

ក៖  ចុះបងជាកូនទៅប៉ុន្មានដែរទៅបង?

ខ៖  ខ្ញុំជាកូនបន្ទាប់៧គេ

ក៖  ចឹងមានន័យថាជាកូនទី7ណាបង?

ខ៖  ចា៎!!នឹងហើយជាកូនទៅ7នឹង

កៈ ចុះសំរាប់ឈ្មោះបងប្អូនរបស់បងនឹងមានឈ្មោះអីគេខ្លះដែរទៅបងបងមានចងចាំទេ?

ខៈ នេះបងណាប្រាប់គាត់បន្តិចទៅ

កៈ អត់ទេបងអាចប្រាប់តិចក៏បានដែរ?

ខៈ មានឈ្មោះអើរបងចាម

កៈ នឹងបងគេណាបង?

ខៈ ចា៎!!នឹងបងគេបង្អស់នឹងឈ្មោះបងចាមនឹង

កៈ អត់ទេអាចប្រាប់ទាំងអ្នកស្លាប់ក៏បានដែរបងប្រាប់ទាំងអស់ហាស?

ខៈ ប្រាប់ទាំងអស់ហើភ្លេចអស់ហើយនឹង

កៈ ចឹងហោសបងបងភ្លេចអស់ហើយណាបង?

ខៈ ឥឡូវនឹងចឹងប្រាប់តែអ្នករស់ៗទៅចឹង

កៈ បាទចឹងក៏បានដែរបង

ខៈ ឈ្មោះបងចាម ឈ្មោះងៃត ឈ្មោះបងណេង ហើយឈ្មោះបងអាំ ឈ្មោះបងណាង ឈ្មោះបងម៉ុក ហើយនឹងខ្ញុំ

កៈ អូ៎!!ចឹងហោសបាទបងបាទ?

ខៈ នៅធីមួយទៀតនឹងពៅគេ

កៈ អូ៎!!បាទបង ចុះសំរាប់បងមានចងចាំសាច់រឿងអីដែរបងគិតថាធ្លាប់ដើរលេងជាមួយគ្នារឺក៏លេងឡឹកបាយឡ រឺមួយលេងបិទពួនអីជាមួយគ្នាដែរទេបង?

ខៈ ធ្លាប់ដែរតើនឹង

កៈ អនុស្សាវរីយ៍អីជាមួយគ្នាកាលពីនៅក្មេងៗហាស
ធ្លាប់បានធ្វើអីគេខ្លះជាមួយក្នាដែរទៅបង?

ខ៖

ថ្លាប់មិត្តទៅមិត្តមកចឹងដល់ពេលនៅលើឈើចឹងទៅហើយខ្ញុំមិត្តទៅហើយកាត់មិត្តមកចឹងទៅ ក៏បានធ្លាក់បាក់ដៃអីចឹងទៅណាស់

ក៖ មិត្តនឹងយ៉ាងម៉េចវិញទៅបង?

ខ៖ មិត្តលេងអាលើឈើហើយរត់ហា អាឈើគេអាហើយគេដាក់កងចឹងហាស

ក៖ អូ៎!!ចឹងហោសបងបាទ?

ខ៖ ហើយវាមានបាសចុងនឹងបាសគល់ចឹងដល់ពេលដៃរគាត់មិត្តមកចុងចឹងទៅ

ក៖ បាទបងបាទចឹង?

ខ៖ ហើយខ្ញុំបានមិត្តទៅគល់ចឹងទៅវាបាសហាស

ក៖ បាទបងបាទនឹង?

ខ៖ ដល់ហើយចឹងក៏បានធ្លាក់មកនឹងបានបាក់ដៃមួយចំហៀងចឹងតែម្ដងនឹង

ក៖ ដលក់ពេលណុងក៏បានឈប់លេងទៅណាបង?

ខ៖ ចា៎!!ដល់ពេលចឹងក៏បានឈប់លេងចឹងទៅ

ក៖ ប៉ុន្តែធ្លាប់បានលេងឡឹកបាយឡ នឹងលេងបិទពួនអីជាមួយគ្នាដៃរតើហីបង?

ខ៖ ធ្លាប់លេងដៃរតើនឹង

ក៖ ប៉ុន្តែធ្លាប់ទៅស្រែទៅអីជាមួយគ្នាដៃរទេបង?

ខ៖ ចា៎!!ធ្លាប់ដៃរនឹងហាសធ្លាប់ទៅស្រែទៅអីចឹង

ក៖ ចុះធ្វើអីគេខ្លះដៃរនៅស្រែនឹងហាសបង?

ខ៖ ទៅស្ទូងស្រូវ នឹងច្រូតស្រូវអីចឹងហាស

ក៖ បាទចឹងហោសបង?

ខ៖ ហើយនឹងស៊ីឈ្នួលគេអីចឹងទៅ

កៈ បាទបង ចុះសំរាប់បងចូលចិត្តលេងអីគេដែរជាមួយបងប្អូនរបស់បងដែរនឹង?

ខៈ ហាសហាចូលចិត្ត

កៈ បងចូលចិត្តលេងអីគេដែរទៅបង?

ខៈ ចូលចិត្តលេងលោតអន្ទាក់លេងអីចឹងទៅមានគ្រប់មុខដែរនឹងហាស

កៈ អូ៎!!បាទបងបាទនឹង?

ខៈ លេងកេះកងកៅស៊ូនឹងដែរ

កៈ អូ៎!!បាទបងបាទចឹងហោស?

ខៈ នឹងលេងអាអីគេលេងអាវៃគក់កន្សែងចឹងហី?

កៈ លេងបោះកន្សែងហីបង?

ខៈ ចា៎!!លេងលាក់កន្សែងអីនឹងលេងច្រើនដែរណាស់ លេងពន្រត់កូនក្រមុំចឹង

កៈ លេងបន្រត់កូនក្រមុំអីចឹង?

ខៈ លេងដណ្តើមស្លឹកឈើចឹងទៅ?

កៈ អូ៎!!អានឹងលេងល្បែងប្រជាប្រិយ៍ណាបង?

ខៈ ចា៎!!នឹងហើយលេងចឹង

កៈ លេងបោះអង្គុញ នឹងទាញព្រាតអីនឹងចឹងហោសបង?

ខៈ ចា៎!!ទាំងអស់នឹងលេងបានទាំងអស់នឹង

កៈ ចុះសំរាប់បងប្អូនរបស់បងនឹងសព្វថ្ងៃគាត់នៅណាដែរទៅបង?

ខៈ នឹងនៅជុំគ្នានៅនឹង ប៉ុន្តែនៅណោះពីរនាក់ នឹងមានបីនាក់ទៀតដែរបែកខ្លះដែរនឹង

កៈ អូ៎!!ចឹងទេហោសបង?

ខៈ គេមានប្រពន្ធមានប្តីនឹងនៅឆ្ងាយៗដែរនឹងហាស

កៈ បាទបង
ចុះពួកគាត់ធ្វើអីគេខ្លះដែរទៅបងសំរាប់ចិញ្ចឹមក្រុមគ្រួសារនឹងចិញ្ចឹមជីវិតដែរចឹងហាសបង?

ខៈ ឪពុករបស់ខ្ញុំពីមុនហោស

កៈ អត់ទេបងប្អូនរបស់បងហាសអ្នកខ្លះបែក
នឹងអ្នកខ្លះដែរនៅម្តុំនឹងហាសបងពួកគាត់ធ្វើអីគេដែរទៅបង?

ខៈ គាត់នៅរកត្រីរកអីដូចតែខ្ញុំដែរនឹងដាំត្រកួន នឹងរកត្រីដែរនឹង

កៈ អូ៎!!បាទបងបាទចឹងចុះ?

ខៈ រយម៉ងរាយអីនឹងចឹង

កៈ អូ៎!!បាទបង ចុះសំរាប់ឪពុករបស់បងនឹងគាត់មានឈ្មោះអីគេដែរទៅបង?

ខៈ គាត់មានឈ្មោះជឿន

កៈ ចុះមានឈ្មោះស្អីគេដែរជឿនហាសបង?

ខៈ គាត់មានឈ្មោះចឹម ជឿន ឪពុករបស់គាត់នឹងឈ្មោះចឹម

កៈ អូ៎!!បាទបាទបងបាទនឹង?

ខៈ ហើយគាត់នឹងមានឈ្មោះចឹម

កៈ អូ៎!!បាទ ចុះឪពុករបស់បងសព្វថ្ងៃនឹងគាត់នៅរស់ដែរតើហីបង?

ខៈ គាត់បានស្លាប់យូរដែរហើយនឹង

កៈ ប៉ុន្តែគាត់នៅដល់អាយុប៉ុន្មានដែរបងមានចងចាំដែរទេបង?

ខៈ គាត់ស្លាប់តាំងពីអាយុ60ឆ្នាំនឹងគាត់ស្លាប់ជាង20ឆ្នាំហើយនឹង

កៈ
គាត់ស្លាប់អស់ប្រហែលជា20ឆ្នាំជាងចឹងមានន័យថាគាត់ប្រហែលជាខ្ទង់80ឆ្នាំអីហើយណាបង?

ខៈ ចា៎!!គាត់ចូលអាយុ80ឆ្នាំជាងហើយនឹង

កៈ អូ៎!!បាទបង ចុះសំរាប់គាត់កើតនៅណាដែរបងមានដឹងទេ?

ខៈ គាត់កើតនៅត្នោតញីនឹងហាស

កៈ ចឹងគាត់នៅត្នោតញីណាបង ចុះម្តាយរបស់បងគាត់មានឈ្មោះអីគេដែរទៅបង?

ខៈ គាត់មានឈ្មោះជោ

កៈ គាត់មានឈ្មោះជោ
ចុះគាត់មកដល់ឥឡូវនឹងគាត់ប្រហែលជាប្អូនតាប៉ុន្មានឆ្នាំដែរទៅបង?

ខៈ គាត់ប្អូនប៉ុន្មានឆ្នាំបងណា គាត់ប្អូនគ្នា4-5ឆ្នាំអីនឹងហាស

កៈ អូ៎!!ចុះគាត់កើតនៅណាដែរទៅបង?

ខៈ ម៉ែរបស់ខ្ញុំនឹងគាត់កើតនៅស្រែនឹងហាស នៅស្រែស្រុកចាប់ ស្រុកអំពិលអីគេនឹង

កៈ បាទបងបាទចុះសំរាប់?

ខៈ នឹងគេហៅនៅតាកែវអីចឹងទៅណាស់

កៈ ចុះសំរាប់គាត់ស្លាប់ដែរណាបង?

ខៈ គាត់ស្លាប់ដែរនឹងមុនក្រោយគ្នាមួយឆ្នាំ

កៈ ចុះឪពុករបស់បងកាលពីគាត់នៅរស់នឹងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិត
ចិញ្ចឹមក្រុមគ្រួសារ នឹងចិញ្ចឹមកូនចៅហាសបង?

ខៈ គាត់ធ្វើចំការ គាត់ធ្វើស្រូវស្រែអីនឹងហាស
រកតែត្រីអីដូចតែយើងឥឡូវនឹងដែរនឹងហាស

កៈ អូ៎!!បាទបងចឹងមានន័យថាគាត់ធ្វើតែមួយនឹងទេគាត់គ្មានធ្វើអីទៀតទេណាបង?

ខៈ អត់មានធ្វើអីទេ

កៈ អូ៎!!បាទ ចុះឪពុករបស់បងគាត់ស្លូតរឺមួយក៏កាចដែរទៅបង?

ខៈ គាត់កាចដែរនឹងហាស

កៈ អូ៎!!គាត់កាចដែរហោសបង?

ខ៖ ចាំ!!នឹងហើយ

ក៖ ចុះម្តាយរបស់បងគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិត នឹងចិញ្ចឹមក្រុមគ្រួសារដែរទៅបង?

ខ៖ គាត់ធ្វើតែស្រូវធ្វើស្រែអីជាមួយគ្នាដែរនឹង

ក៖ អូ៎!!ចឹងហោសបង?

ខ៖ ប៉ុន្តែម្តាយរបស់ខ្ញុំនឹងគាត់ស្លូត ឪពុករបស់ខ្ញុំអាយុ64 ហើយម្តាយអាយុ60ឆ្នាំ

ក៖ អូ៎!!សុទ្ធតែបងប្អូនទាំងអស់ហោសបង?

ខ៖ ចាំ!!គាត់អាយុមួយ64ឆ្នាំហើយមួយទៀតអាយុ60ឆ្នាំខុសគ្នា4ឆ្នាំនឹង

ក៖ អូ៎!!បងប្អូននៅជុំគ្នាទាំងអស់នឹង?

ខ៖ នឹងហើយចឹង

ក៖
ចុះបងគិតថាកាលពីបងនៅជាមួយឪពុកម្តាយរបស់បងនឹងបងធ្លាប់មានអនុស្សាវរីយ៍អីគេខ្លះដែរ ទៅបងហោស?

ខ៖ ថាម៉េច?

ក៖ ធ្លាប់មានអនុស្សាវរីយ៍អីកាលពីឪពុកម្តាយរបស់បងនៅរស់ហាស
ដូចថាបងទៅដើរលេងជាមួយគាត់
រឺមួយក៏ទៅស្រែអីជាមួយគាត់ដែរបងគិតថាបងចងចាំអត់ភ្លេចហាស?

ខ៖ មានធ្លាប់មានដែរតើ!!

ក៖ ធ្លាប់បានធ្វើអីគេខ្លះដែរទៅបង?

ខ៖ ធ្លាប់ទៅរើសស្វាយទុំជាមួយគាត់ដើរមើលគេចឹងទៅយើងដឹកដៃគាត់

ក៖ អូ៎!!បាទបងបាទនឹង?

ខ៖ ពេលយប់ហាស

យប់ដូចថាគាត់ចាស់ហើយគាត់មើលអីមិនសូវឃើញចឹងទៅយើងបានដឹកដៃគាត់ចឹងហាសអោយទៅមើលជំងឺគេហាស

ក៖ អូ៎!!បាទបងបាទនឹង?

ខ៖ ដោយសារតែគាត់ជាគ្រូខ្មែរ

ក៖ អូ៎!!ចឹងហោសបង

ចុះបងគិតថាឪពុករបស់បងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិកាលពីគាត់នៅក្មេងទៅបងដែរទេបង?

ខ៖ គាត់អត់ដែរបាននិយាយផង

ក៖ អូ៎!!ចុះម្ដាយរបស់បងគាត់មានដែរប្រាប់ពីប្រវត្តិអីទៅបងដែរទេ?

ខ៖ ខ្ញុំអត់ដែរនឹង

ក៖ ចឹងអត់ដែរនឹង ចុះសំរាប់យាយតាខាងឪពុកបងមានស្គាល់ឈ្មោះគាត់ដែរទេ?

ខ៖ ខ្ញុំស្គាល់ដែរតើនឹង

ក៖ គាត់មានឈ្មោះអីគេដែរទៅបង?

ខ៖ ពួកគាត់មានឈ្មោះអើរយាយភី នឹងតាចឹម

ក៖ ចុះគាត់កើតនៅណាដែរបងមានដឹងទេ?

ខ៖ គាត់នៅស្រុកគាត់ណុងត្នោតញីនឹងតែម្ដងនឹង

ក៖ ចុះយាយតាខាងឪពុកវិញ មិញយាយតាខាងឪពុករឺមួយខាងម្ដាយ?

ខ៖ មិញនឹងខាងឪពុកនឹងហាស

ក៖ ចុះយាយតាខាងម្ដាយវិញបង?

ខ៖ ខាងម្ដាយរបស់ខ្ញុំនឹងនៅស្រែហោស

ក៖ ប៉ុន្តែគាត់មានឈ្មោះអីគេខ្លះដែរទៅបងមានចងចាំឈ្មោះគាត់ដែរទេ?

ខ៖ គាត់មានឈ្មោះយាយចិននឹងតាដៃ

ក៖ អូ៎!!បាទប៉ុន្តែគាត់កើតនៅខាង?

ខ៖ គាត់កើតនៅស្រែកើតនៅខាងតាកែវនឹង

ក៖ អូ៎!!បាទចុះបងមករស់នៅនឹងយូរនៅបង?

ខ៖ ខ្ញុំមករស់នៅជាង10ឆ្នាំហើយនឹង

ក៖ អូ៎!!បាទបង ចុះបងមានបងប្អូនរឺមួយក៏កូនចៅណាដែររស់នៅក្រៅប្រទេសដែរទេបង?

ខ៖ អត់មានផងនឹងមានតែនៅក្នុងប្រទេសយើងអីនឹង

ក៖ ទៅធ្វើការងារនៅថៃ នៅវៀតណាមអីក៏អត់មានដែរណាបង?

ខ៖ ចា៎!!អត់មានផងនឹង

ក៖ អូ៎!!បាទបងបាទ ចុះសំរាប់ស្វាមីរបស់បងនឹងគាត់មានឈ្មោះអីគេដែរទៅបង?

ខ៖ គាត់មានឈ្មោះឌឿន ឈ្មោះដន ឌឿន ឪពុកគាត់ឈ្មោះដន គាត់មានឈ្មោះឌឿន

ក៖ ចុះបងរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរបងមានចងចាំទេ?

ខ៖ អត់មានចងចាំផងនឹង

ក៖ ប៉ុន្តែឆ្នាំហាសបងមានចងចាំដែរទេ?

ខ៖ អត់អត់ចងចាំទេខ្ញុំភ្លេចអស់ហើយនឹង

ក៖ ប៉ុន្តែចុះកូនរបស់បងនឹងគាត់មានឈ្មោះអីគេដែរទៅបង
អូមិនមែនទេបងចង់និយាយថាគាត់អាយុ ប៉ុន្មានដែរបងឥឡូវនឹងហាស?

ខ៖ កូនរបស់ខ្ញុំហោស?

ក៖ បាទកូនធំរបស់បងហាស?

ខ៖ នេះគាត់អាយុ23ឆ្នាំនឹង

កៈ ចឹងគាត់អាយុ23ឆ្នាំហោសបង ចុះនៅពាលដែរបងការហើយនឹងដូចជាបងនៅទំនេរពោះសិន រឺមួយក៏បងមានកូនតែម្ដងនឹងហោសបង?

ខៈ ការហើយអស់3-4-5ឆ្នាំដែរនឹងបានមានកូន

កៈ អូ៎!!ចឹងហោសបង ចឹងមានន័យថាបងការនឹងអស់ប្រហែលជា25-26ឆ្នាំហើយហោសបង?

ខៈ ចា៎!!វាចឹងហើយនឹង

កៈ ចុះបងគិតថាពេលដែរបងការនឹងបងគិតថាបងជាអ្នករៀបចំដោយចិត្តខ្លួនឯង រឺមួយក៏ឪពុកម្ដាយគាត់ជាអ្នករៀបចំអោយដែរបង?

ខៈ ម៉ែឪរបស់គាត់មកដែរតើ!!

កៈ អូ៎!!បាទ ចុះដូចជាប្ដីរបស់បងចូលស្ដីដណ្ដឹងបងនឹងដូចជាមានជាជំនូនជូនបងដែរទេ?

ខៈ អត់ទេគ្មានវាអត់ដែរនឹងដល់ពេលចឹងយើងនឹកឃើញអាណិតហាស ចេះតែយកចេះតែ

កៈ អូ៎!!យើងយល់គ្នាណបង?

ខៈ ចា៎!!យល់គ្នានឹងហាស

កៈ បាទបង ចុះ?

ខៈ ដូចថាខ្ញុំលយកអីពីគាត់ចឹងហាសគាត់បានយកលុយមកខ្លះហើយបានរៀបចំអីជាមួយយើងខ្លះដែរ ចឹងទៅណាស់វាចឹង ការអោយហើយមួយថ្ងៃនឹង

កៈ យើងចែកគ្នាចេញចឹងទៅណបង?

ខៈ ចា៎!!នឹកឃើញថាគ្នាអត់ដែរនឹងហាស

កៈ បាទបងបាទ ចុះដូចជាបងធ្លាប់ស្គាល់ប្ដីរបស់បងពីមុនទេពេលមុនការជាមួយគ្នាហាស?

ខៈ អត់ដែរស្គាល់ផងនឹង

កៈ ចឹងអត់ដែរស្គាល់គ្នាទេ ចឹងមានន័យថាម្ដាយឪពុកជាអ្នកណែនាំអោយស្គាល់រឺមួយក៏យ៉ាងម៉េចដែរទៅបង?

ខៈ គាត់បានធ្លាប់មកធ្វើរកង់ធ្វើរអីនឹង គាត់មកច្រូតស្រូវអីនៅក្រោយផ្ទះនឹងហាស

កៈ អូ៎!!ចឹងទេហោសបង?

ខៈ ដល់ពេលដែរគាត់មកធ្វើរកង់ចឹងទៅគាត់បានមកស្គាល់បងៗរបស់ខ្ញុំនឹងហាស ប៉ុន្តែខ្ញុំអត់ដែរបានស្គាល់គាត់ទេ

កៈ អូ៎!!បាទបងបាទ?

ខៈ ពីព្រោះនៅម៉ូងខ្ញុំទៅផ្ទះមីងហាស

កៈ បាទបងបាទនឹង?

ខៈ ខ្ញុំមានផ្ទះបងប្អូននៅម៉ូងបានធ្វើរកង់ធ្វើរអីចឹងទៅ ហើយគាត់បានឃើញគាត់ស្រលាញ់យើងចឹងទៅ គាត់បានរាយរាប់បងរបស់យើងចឹងទៅណាស់

កៈ បាទបងបាទនឹង?

ខៈ ថាគាត់ស្រលាញ់យើងចឹងហាស

កៈ អូ៎!!ចឹងហោសចឹងបានគាត់បានអោយឪពុកម្ដាយរបស់គាត់មកចូលស្ដីដណ្ដឹងមីង?

ខៈ ចា៎!!នឹងហើយចឹងតាមពិតអត់ដែរស្គាល់គាត់ផងនឹង

កៈ បាទចឹងសំរាប់ដូចជាបងធ្លាប់បានរៀនបានថ្នាក់ទីប៉ុន្មានដែរបង?

ខៈ ខ្ញុំរៀនបានតែថ្នាក់ទី2នឹងខ្ញុំឈប់រៀនទៅ ចុះយើងវាពិបាកពេកអត់មានអីហូបហាស

កៈ បាទបងបាទចុះកាលពីបងរៀននឹងបងរៀននៅណាវិញបង?

ខៈ ខ្ញុំរៀននៅត្នោតញីនឹងហាស

កៈ ចឹងបងរៀននៅត្នោតញីណាបង?

ខៈ ចា៎!!នឹងហើយ

កៈ ចុះបងមានចេះភាសាអីក្រៅពីភាសាខ្មែរដែរទេបង?

ខៈ អត់ផងនឹងចេះតែមួយមុខនឹង

កៈ ចុះភាសាថៃ នឹងភាសាវៀតណាមអីបងមានចេះទេ?

ខៈ ខ្ញុំអត់ចេះផងនឹងចេះតែភាសាខ្មែរនឹង

កៈ អូ៎!!បាទបងបាទ ចុះបង?

ខៈ ភាសាថៃនឹងចេះបានតែពីរបីម៉ាត់ទេ

កៈ ចុះបងធ្លាប់បានទៅប្រទេសថៃទេបង?

ខៈ ចា៎!!ធ្លាប់ទៅប្រទេសថៃទៅស៊ីឈ្នួលច្រូតអោយថៃដែរនឹង ចេះបានតែបីម៉ាត់ទេនឹង

កៈ អូ៎!!ចុះបងគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះហាស តើបងធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលដែរ ធំធាត់មកជាមួយគ្នាដែរទេបង?

ខៈ ខ្ញុំធ្លាប់មានដែរប៉ុន្តែឥឡូវនឹងគេមានប្តីមានអីអស់ហើយនឹង

កៈ អូ៎!!ប៉ុន្តែពួកគាត់មានឈ្មោះអីគេខ្លះដែរបងមានចងចាំឈ្មោះពួកគាត់ដែរទេ?

ខៈ ខ្ញុំចងចាំដែរតើមានឈ្មោះសារ៉េត ឈ្មោះឡុង ឈ្មោះអេន តែបីនាក់នឹងទេ

កៈ អូ៎!!ប៉ុន្តែនេះជាមិត្តភក្តិដែរជិតស្និទ្ធិរបស់បងមែនទេ?

ខៈ ចា៎!!ធ្លាប់ដើរជាមួយគ្នា នឹងធ្លាប់បានរៀនជាមួយគ្នាអីចឹងទៅ

កៈ បាទបងចុះបងធ្លាប់មានអនុស្សាវរីយ៍អីជាមួយពួកគាត់ដែរទេ?

ខៈ ធ្លាប់មានដែរតើធ្លាប់បានដើរលេងជាមួយគ្នា ដល់ហើយថតជាមួយគ្នាចឹងទៅ

កៈ បាទបងបាទ?

ខៈ បានម្នាក់ពីរបីប៉ុសដែរតើនឹង

កៈ អូ៎!!បាទចុះបងធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរមែនទេបង?

ខៈ ខ្ញុំធ្លាប់ដែរតើនឹង

កៈ ប៉ុន្តែបងធ្វើអីគេដែរនៅវាលស្រែនឹងហោសបង?

ខៈ ច្រូតស្រូវនឹងច្រូតស្រូវជាមួយគ្នានឹងហាស

កៈ ប៉ុន្តែជីវិតរបស់បងហាស
តើបងធ្លាប់ទៅធ្វើការងារនៅវាលស្រែនឹងបងធ្លាប់ធ្វើអីគេខ្លះដែរទៅបង?

ខៈ មានអីទេមានតែច្រូតស្រូវនឹង

កៈ មានច្រូតកាត់អីចឹងទៅហោសបង?

ខៈ មានតែច្រូត ដកសំណាបអីចឹងហាស

កៈ ចុះសំរាប់បងមានធ្លាប់ធ្វើចំការដែរទេបង?

ខៈ ខ្ញុំធ្លាប់ដាំត្រសក់ដាំអីដែរនឹងហាស

កៈ ចុះសំរាប់បងគិតថាបងតាំងពីក្មេងរហូតដល់ពេលនេះ
តើបងធ្លាប់ធ្វើការងារអីគេនៅក្នុងជីវិតរបស់បងដែរ?

ខៈ ខ្ញុំធ្លាប់ធ្វើសំណង់អីធ្លាប់ធ្វើគ្រប់មុខទាំងអស់នឹងហាស
ទៅធ្វើសំណង់ហើយដល់ពេលហើយយើងទិញពោតគេយកមកដឹកស្មោរលក់នឹង
មានវេចនុំលក់

កៈ អ៊ូ!!បាទបងបាទ?

ខៈ មានច្រើនដែរនឹងហាស

កៈ បាទបង ចុះបងគិតថាបងធ្លាប់បើកអាជីវកម្មមុខរបរអីគេដែរទេបង?

ខៈ អត់ដែរបានបើកអីផង យើងមានតែរកត្រីរកអីលក់នឹង
ហើយនឹងយើងដឹកស្ពីៗៗយកទៅលក់បានតិចៗៗចឹងទៅណាស់

កៈ អ៊ូ!!បាទបងបាទ ចុះបងមានធ្លាប់ចិញ្ចឹមសត្វទេ ចិញ្ចឹមមាន់ ចិញ្ចឹមគោ
ចិញ្ចឹមក្របីអីចឹងហាស?

ខៈ ខ្ញុំធ្លាប់បានចិញ្ចឹមដែរតើ

កៈ ចុះបងធ្លាប់ចិញ្ចឹមអីគេដែរទៅបង?

ខៈ ធ្លាប់ចិញ្ចឹមមាន់ប៉ុន្តែឥឡូវនឹងដូចថាចោរវាលួចច្រើនពេកចឹងឈប់ចិញ្ចឹមហើយនឹង

កៈ អូ៎!!បាទបងបាទចឹង?

ខៈ មានចិញ្ចឹមមាន់ ចិញ្ចឹមទាកាប៉ាអីនឹងហាស

កៈ អូ៎!!ប៉ុន្តែបងចិញ្ចឹមច្រើនរឺមួយចិញ្ចឹមតិចដែរទៅបង?

ខៈ មានចិញ្ចឹមច្រើនដែរនឹងមានដាក់បួនទៅដប់សំបុកអីដែរនឹងហាស

កៈ អូ៎!!ចឹងហោសបង?

ខៈ ប៉ុន្តែមួយថ្ងៃៗៗយើងអត់នៅផ្ទះទៅគេលួចអស់ទៅឈប់ចិញ្ចឹមទៅ

កៈ អូ៎!!បាទបង ចុះបងគិតថាជីវិតរបស់បងតាំងពីក្មេងរហូតមកដល់ពេលនេះហាស តើជីវិតរបស់បងមានការផ្លាស់ប្តូរអីគេដែរទៅបង?

ខៈ មានការផ្លាស់ប្តូរដែរនឹងហាស

កៈ មានការផ្លាស់ប្តូរអីគេខ្លះដែរទៅបង?

ខៈ ដូចថាយើងប៉ុន្តែយើងរកក៏ចេះដែរជួនបានជួនអត់មួយប្រ៉ាវៗៗចឹងទៅណាស់

កៈ បាទបងបាទនឹង?

ខៈ យើងរកបានមួយប្រ៉ាវចឹង ដល់ពេលដែរយើងរកអត់បានចឹង យើងលក់ស៊ីវិញអស់មួយប្រ៉ាវចឹងទៅណាស់

កៈ អូ៎!!បាទបងចឹង?

ខៈ ប៉ុន្តែយើងមានជំពាក់គេជំពាក់អីដែរនឹង មានជំពាក់លុយគេលុយរាប់អីដែរនឹងហាស

កៈ អូ៎!!ចឹងហោសបង?

ខៈ
ចាំ!!ដោយសារតែយើងខ្លាចអត់អីអោយកូនស៊ីយើងចេះតែរកចឹងទៅធ្វើសំណាង់អីចឹងទៅ

កៈ បាទបងបាទចឹង?

ខ៖ ប្តីរបស់ខ្ញុំនឹងគាត់ទៅធ្វើសំណង់ដែរតើនឹង

ក៖ នៅសព្វថ្ងៃនឹងហោសបង?

ខ៖ គាត់ធ្វើនៅជិតគល់ស្ពានអាស្ពានឆាក្តៅយើងនៅខាងក្រៅនឹងហាស

ក៖ បាទបងខ្ញុំស្គាល់បង ចុះបងគិតថាបងចូលចិត្តពិសារម្ហូបអីគេដែរទៅបង?

ខ៖ ខ្ញុំចូលចិត្តតែសំលម្ជូរ

ក៖ ចូលចិត្តសំលម្ជូរ ចុះឆា ស្ងោរ ការី ចៀនអីនឹងបងចូលចិត្តដែរទេ?

ខ៖ ខ្ញុំចូលចិត្តដែរនឹង ចូលចិត្តសំលកកូរមួយ នឹងចូលចិត្តសម្លម្ជូរយួន

ក៖ អូ្ន!!ចឹងទេ?

ខ៖ ឆាមិនសូវបានចូលចិត្តទេនឹងហាស

ក៖ បាទបងបាទ ចុះបងគិតថាល្បែងប្រជាប្រិយ៍អីគេដែរបងចូលចិត្តលេងដែរបង កាលពីនៅក្មេងហាសបង?

ខ៖ ខ្ញុំចូលចិត្តលេងនឹងមានតែបោះឈូង ហើយនឹងដណ្តើមស្លឹកឈើ

ក៖ អូ្ន!!បាទបងបាទ?

ខ៖ ហេអត់ចេះខ្មាស់គ្រូទេហីគ្រូវៃហាស

ក៖ ចុះសំរាប់បងគិតថាបងចូលចិត្តច្រៀងដែរទេបង?

ខ៖ ចូលចិត្តដែរតើនឹង

ក៖ លក្ខណះថាបងចូលចិត្តបទបុរាណ រឺមួយបទសម័យដែរបង?

ខ៖ បទសម័យហី

ក៖ អូ្ន!!បទសម័យហោសបង?

ខ៖ អាបទដូចថាពួកខេមរះអីច្រៀងនឹងខ្ញុំចូលចិត្តដែរតើ

ក៖ អូ្ន!!បទសម័យណាបង?

ខ៖ ចាំ!!នឹងហើយបទនឹង

ក៖ ចុះបងចូលចិត្តស្តាប់បទចំរៀងដែរទេបង?

ខ៖ ខ្ញុំចូលចិត្តដែរតើនឹង

ក៖ លក្ខណះបទបុរាណរឺមួយបងសម័យដែរបងដែរបងចូលចិត្តហាស?

ខ៖ បទសម័យប៉ុន្តែមានអត្ថន័យអីនឹង

ក៖ អូ៎!!បាទបងបាទ?

ខ៖ ប៉ុន្តែអាបទអាលេសអាលោសប្រកាចរាំវិលក្បុងអីនឹងអត់ចូលចិត្តទេនឹង

ក៖ បាទបងបាទ?

ខ៖ ដូចជាបទព្រាបសុវត្តិអីចឹងហាស

ក៖ បាទបងបាទចឹងហោស?

ខ៖ ហើយនឹងបទស្អីគេទេបទឧសុកុនកញ្ញានមឹង មិនមែនទេអត់ទេស្លាប់បាត់ហើយនឹង

ក៖ អ្នកស្លាប់នរណាគេដែរបង?

ខ៖ អត់ទេកាលជំនាន់ពីមុនហាស

ក៖ កាលពីដើមហោសបទស៊ិនស៊ីសាម៉ុត?

ខ៖ មិនមែនទេនឹងរៀងក្មេងជាងគេហាស

ក៖ ខ្ញុំអត់ស្គាល់ដែរផងនឹងហាស?

ខ៖ បទកែវសារ៉ាត់ នឹងបទកែវសារ៉ាត់នឹងហាស

ក៖ អូ៎!!បទកែវសារ៉ាត់ ដែរបងចូលចិត្តច្រៀងដែរហោសបង?

ខ៖ ចាំ!!ខ្ញុំចូលចិត្តលគាត់នឹង

កៈ
ចុះបងគិតថាមាននរណាម្នាក់មួយនៅក្នុងក្រុមគ្រួសាររបស់បងចេះលេងឧបករណ៍ភ្លេងដែរទេប
ង?

ខៈ អត់មានផងនឹង

កៈ ចឹងអត់មាននរណាចេះលេងភ្លេងទេហោសបង?

ខៈ ពីមុនកូនលេងស្អីគេនេះនឹងដែរប៉ុន្តែឥឡូវនឹងវាឈប់ហើយនឹងហាស
លេងគេហៅអីគេ

កៈ លេងអកកណ្ដុងហោសបង លេងអីគេបង?

ខៈ លេងអក

កៈ លេងអក?

ខៈ នៅលើព្រះវិហារនេះនឹងហាស

កៈ អូ៎!!លក្ខណៈថាតន្ត្រីពួកបរទេសនឹងហោសបង?

ខៈ ចាំ!!នឹងហើយពួកយេស៊ូវនឹងហាស គេទិញយកមកអោយយើងលេងហាស

កៈ ចុះមាននរណាគេមួយបង សំទោសបង
ចុះផ្ទះរបស់បងនឹងមានលក្ខណៈបែបណាដែរបងតាំងពីក្មេងរហូតមកដល់ពេលនេះហាស
?

ខៈ ផ្ទះនៅស្រុកនឹងមែន?

កៈ បាទផ្ទះកាលនៅពីក្មេងផ្ទះយ៉ាងម៉េចដែរ?

ខៈ ផ្ទះនៅស្រុកនឹងផ្ទះចឹងទាបចឹង មានកំពស់នឹង

កៈ អូ៎!!ប៉ុន្តែជាផ្ទះឈើចឹងមែនទេបង?

ខៈ ផ្ទះឈើនឹងហាសផ្ទះឈើពីមុនហាសនៅជំនាន់អាពតហោស

កៈ ប៉ុន្តែនរណាគេជាអ្នកសាងសងផ្ទះមួយណុងដែរបង?

ខ៖ ម៉ែឪនឹងប៉ុន្តែឥឡូវនឹងផ្ទះនឹងរុះអស់ហើយនឹង

ក៖ ប៉ុន្តែផ្ទះដែរធ្វើនឹងគេមានប្រើឧបករណ៍អីគេខ្លះដែរសំរាប់សាងសងផ្ទះណុងដែរបង?

ខ៖ ផ្ទះណុងពីមុននឹងមានតែគេប្រកអាស្ពឺគេប្រកគក់

ក៖ គេប្រកគក់?

ខ៖ មិនមែនប្រគក់ទេឥឡូវនឹងទើបតែចេញពីឥឡូវនឹង

ក៖ បងអត់ស្គាល់គក់ បងអត់ស្គាល់អីទេ?

ខ៖ ផ្ទះពីមុនប្រក់ស័ង្កសីនឹងប្រក់អីនឹងគ្រាន់វាចាស់ហាស

ក៖ បាទបងបាទ?

ខ៖ ដល់ពេលយើងឥឡូវនឹងប្រកគក់ប្រកអីនឹងប្រកស្បូវអីនឹង

ក៖ ចុះសំរាប់បងគិតថាប្តីរបស់បងនឹងចេះធ្វើផ្ទះដែរទេបង?

ខ៖ គាត់ចេះតែចាក់សាបនឹង

ក៖ អូ៎!!បាទបងបាទ?

ខ៖ ចាក់សាប នឹងបណ្តុះសសរអីចឹងហាសបានគាត់ចេះធ្វើហាស

ក៖
បាទបងបាទនឹងចុះបងគិតថាជំនាញអីដែរបងគិតថាបងចេះស្ទាត់ជំនាញដែរហាសបង?

ខ៖ ខ្លួនរបស់ខ្ញុំនឹងមែន?

ក៖ បាទបងចេះធ្វើអីគេដែរបង?

ខ៖ អូ៎!!ខ្ញុំនឹងបើនិយាយទៅដូចជាចាប់ឆាយនឹងតែម្តងនឹងហាស

ក៖ អូ៎!!ចាប់ឆាយនឹងតែម្តងហោស រកត្រកួនរឺមួយធ្វើស្រែធ្វើអីចឹងទៅ?

ខ៖ ចា៎!!មានតែស្រូវ ធ្វើស្រូវធ្វើអីមានតែបេះត្រកួននឹងរាយម៉ងរាយសន្ទូចអីនឹងបាន

កៈ អូ!!បាទបងបាទនឹង
ចុះនរណាគេបង្រៀនបងអោយចេះវាយម៉ងនឹងវាយសន្ទូចនឹងបង?

ខៈ អត់ទេចេះខ្លួនឯងតែម្តងនឹងហាស

កៈ ចេះខ្លួនឯងណោះបង ចុះបង?

ខៈ កើតមកឃើញគេវាយចឹងទៅចេះតែវាយតាមគេតាមឯងចឹងទៅ

កៈ ចុះលក្ខណះថាម្តាយឪពុកបងគាត់មានធ្លាប់បង្រៀនពីជំនាញអីទៅបងដែរទេ?

ខៈ ដូចថាយើងកើតមកនឹងឃើញគាត់ធ្វើចឹងហើយយើងចេះតែធ្វើតាមចឹងទៅណាស់

កៈ អូ!!បាទបង
ចុះបងគិតថាកាលពីក្មេងរហូតមកដល់ពេលនេះហាសបងមានការលំបាកអីគេខ្លះដែរនៅក្នុងជីវិតរបស់បងដែរចឹងហាស?

ខៈ
អូ!!បើនិយាយរឿងពិបាកនឹងពិបាករហូតនឹងហាសមកដល់ឥឡូវនឹងខ្ញុំមិនទាន់ស្រណុកផងនឹង

កៈ ចុះបងគិតថាកាលពីក្មេងនឹងបងមានការលំបាកអីគេដែរបងគិតថាបងមានបញ្ហាសំរាប់ជីវិតរបស់បងដែរចឹងហាស?

ខៈ
កាលនៅជាមួយម៉ែជាមួយឪនឹងយើងទៅរៀនចឹងទៅពេលមកវិញបាយនឹងប៉ុនៗៗកដៃហាស បាយលាយជាមួយពោតហាស

កៈ បាទបងបាទនឹង?

ខៈ
ហើយដល់ពេលចឹងទៅយើងក៏មិនបានរៀនបានសូត្រដែរចឹងយើងឃើញគាត់ពិបាកពេកក៏យើងឈប់រៀនចឹងទៅយើងក៏ទៅស៊ីឈ្នួលគេ

កៈ បាទបងបាទនឹង?

ខ៖  ដល់ពេលចឹងយើងនឹកឃើញរៀននឹងម៉ែឪនឹងគាត់រៀងចាស់ៗដែរហើយនឹង គាត់មិនដឹងថាធ្វើអីគេគាត់ចេះតែយកស្រូវគេអីចឹងមកក៏អោយយើងយកទៅសងអោយគេ អាស្នង អាអីចឹងទៅណាស់

ក៖  បាទបងបាទ?

ខ៖  គេយកថ្ងៃហាស គេយកថ្ងៃយើងហាស

ក៖  បាទបាទបងបាទ?

ខ៖  គេយកដូចថាគេយកមួយតៅចឹងយកយក5-6ថ្ងៃអីចឹងយើងទៅសងគេចឹងទៅណាស់

ក៖  បាទបងបាទនឹង?

ខ៖  នាំបងប្អូនទៅសង
ដល់ពេលចឹងយើងនឹកឃើញថារៀននឹងក៏មិនបានចប់ចុងចប់ដើមដែរណាស់

ក៖
ចុះបងគិតថានៅពេលដែរបងមានគ្រួសារនឹងបងគិតថាបងមានការលំបាកអីគេខ្លះដែរទៅ បង ពេលដែរបងចាប់ដៃជាមួយប្តីរបស់បងដំបូងៗចឹងហាស?

ខ៖  ចា៎!!ពិបាកដែរនឹងហាសរកស៊ីជាមួយតែគ្នានឹងហាស

ក៖  អូ៎!!ចឹងហោសបងហោស?

ខ៖  ចា៎!!ខ្ញុំទើបតែបានឈប់បានពីរបីថ្ងៃនឹងទេ

ក៖  អូ៎!!ដល់ពេលក្រោយមកបងទៅវាយបន្តទៀតមែនទេបង?

ខ៖  ចា៎!!នឹងហើយទៅវាយទៀតនឹងហាស

ក៖  បងភាគច្រើនបានវាយបានជាត្រីហើយបងយកទៅលក់នៅផ្សារចឹងទៅ?

ខ៖  ចា៎!!យកទៅលក់នៅផ្សារនៅផ្សារតាខ្មៅនឹងហាស

ក៖  បាទបងបាទចុះត្រកួនអីបងដូចជាបងជួលគេ?

ខ៖  ត្រកួននឹងជួលដីគេនឹង

ក៖  ចឹងបងជួលដីគេហោសបង?

ខ៖  ចា៎!!មួយហត្ថាចឹង500$-600$នឹងហាស
ហើយយើងអត់លុយចឹងយើងទៅយកលុយរាប់មកអោយ គេចឹងទៅណាស់

ក៖  បាទបងបាទ?

ខ៖
ហើយដល់ពេលដែរយលងបេះបានចឹងទៅនឹងហើយចេះហូបខ្លះយើងអោយគេខ្លះដែរចឹង
ហាស ចេះតែបណ្តុះគេចឹងទៅណាស់

ក៖  អូ៎!!បាទបងបាទ
ចុះបងកិតថាបងឆ្លងកាត់ការលំបាកមួយនឹងទាំងអស់នឹងដោយរបៀបណាដែរបង?

ខ៖  អើរនិយាយទៅពិបាកណាស់ដែរនឹង

ក៖  អូ៎!!បាទបង
ចុះបងគិតថាពេលណាដែរបងគិតថាជាពេលដែរសប្បាយនៅក្នុងឆាកជីវិតរបស់បងដែរទៅ
បង?

ខ៖  នឹកឃើញមិនដឹងថ្ងៃណាបានទេតាល់តែយើងធូរធារដែរនឹង
ដូចថាចិញ្ចឹមកូនអោយត្រើសៗចឹង
កូនអាចទៅជួយស៊ីឈ្នួលគេបានជំនួសដៃជំនួសជើងយើងចឹង
ហើយចាស់ឡើងយើងរៀងធូរយ៉ាងម៉េច អានឹងយើងមិនដឹងទេណាស់

ក៖  បាទបងបាទនឹង?

ខ៖  ថ្ងៃមុខនឹងយើងមើលមិនឃើញដែរចឹងហាស

ក៖  ចុះបងមានកូនចៅជំនួនប៉ុន្មាននាក់ដែរទៅបង?

ខ៖  ខ្ញុំមានកូន6នាក់

ក៖  អូ៎!!បងមានកូន6នាក់ហោស ពួកគាត់សុទ្ធតែជាកូនចៅរបស់បងទាំងអស់ហោសបង?

ខ៖  ចា៎!!អានេះកូនក្មួយកូនបងរបស់ខ្ញុំមិញនឹង

កៈ អូ!!ប៉ុន្តែបង?

ខៈ កូនរបស់ខ្ញុំនឹងនៅម្តុំនេះទាំងអស់នឹងអានេះអិរិននឹងហាស

កៈ ចឹងនៅម្តុំនឹងសុទ្ធតែបងប្អូនកូនចៅរបស់បងទាំងអស់ហោសបង?

ខៈ ចា៎!!បងប្អូនមាន3-4-5នាក់នឹងហាស

កៈ អូ!!មានច្រើនហាសណាបង?

ខៈ ចា៎!!នឹងហើយ

កៈ ចុះបងធ្លាប់គិតថាកាលពីក្មេងហាសបងធ្លាប់មានក្តីស្រម៉ៃថាពេលដៃរធំឡើងនឹងហាស បងចង់ធ្វើអីគេដែរទេបង?

ខៈ អូយដូចជារៀងភ្លេចអស់ហើយនឹង

កៈ ចុះបងធ្លាប់គិតថាកាលពីក្មេងនឹងបងធ្លាប់គិតថាបងចង់ធ្វើជាគ្រូបង្រៀន រឺមួយក៏ចង់ធ្វើជាគ្រូពេទ្យអីចឹងហាសបង បងធ្លាប់គិតដែរទេ?

ខៈ ខ្ញុំធ្លាប់គិតដែរតើ ប៉ុន្តែយើងចង់និយាយថាទៅណាយើងវាអត់ពេកហាស

កៈ អូ!!បាទបង ចុះបើសិនជាចង់អោយបងផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗរបស់បងនឹង តើបងចង់ផ្តែផ្តាំអីគេខ្លះដែរទៅពយកគាត់ដែរបង?

ខៈ អើរខ្ញុំមិនដឹងថាផ្តែផ្តាំយ៉ាងម៉េចទេនឹង

កៈ លក្ខណៈថាអោយពួកគាត់ខំប្រឹងរៀនដើម្បីអោយពួកគាត់មានអនាគត់ល្អអីចឹងហាស

ខៈ នឹងរាល់ថ្ងៃនឹង សុខចិត្តថាអោយយើងពិបាកតែពីរនាក់ប្តីប្រពន្ធចឹងទៅ អោយវាខំប្រឹងរៀននឹងអោយ វាបានធូរហាសកុំអោយពិបាកដូចយើងនឹងហាស

កៈ បាទបងបាទនឹង?

ខៈ ក្រែងឡូវាបានទៅស្រុកក្រៅអីនៅប្រទេសគេទៅយើងក៏វាបានធូរដែរចឹងហាស

កៈ បានធូរធារដែរហោសបង?

ខៈ ចា៎!!នឹងហើយចឹង

ក៖ ចុះបើសិនជាលក្ខណៈថាអោយពួកគាត់ជៀសវៀងវិញហាស
តើបងចង់អោយពួកគាត់ជៀសវៀងអីគេដែរបងសំរាប់កូនចៅតរបស់បងហាស?

ខ៖ អោយជៀសវៀងរឿងគ្រឿងញៀនអីចឹងទៅណាស់

ក៖ បាទបងបាទនឹង?

ខ៖ ហើយនឹងផឹកស្រាផឹកអីនឹងក៏មិនចង់អោយផឹកដែរនឹងហាស
និយាយអោយចំទៅចង់អោយតែវាខំ រកស៊ីអោយមានអោយបានចឹងទៅ
កុំអោយវាប្រព្រឹត្តនៅអំពើថោកទាបអីដែរចឹងហាសខ្ញុំអត់ចូលចិត្ត ដែរនឹងហាស

ក៖ បាទបងបាទនឹង?

ខ៖ ប៉ុន្តែកូនខ្លះយើងប្រដៅអត់បានចឹងហាស

ក៖ វាពិបាកដែរណាបង?

ខ៖ ចា៎!!វាអត់ស្តាប់យើងនឹងហាស

ក៖ បាទបងមានអីដែរបងចង់ផ្តែផ្តាំផ្សេងទៀតទេបង?

ខ៖ អត់មានអិផងនឹង

ក៖
បាទបងចឹងជាចុងក្រោយខ្ញុំអរគុណច្រើនបងដែរបានអោយខ្ញុំពិភាក្សាជាមួយបងដែរទាក់ទ
ងពីប្រវត្តិ
របស់បងហើយខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នេះទៅក្នុងវេបសាយរបស់សាលា
ដើម្បីតំកល់ទុកអោយកូនចៅជំនាន់ក្រោយៗៗរបស់បងបានស្គាល់នឹងបានដឹងចឹងហាសប
ង?

ខ៖ ចា៎ៗៗ!!នឹងហើយ

ក៖ បាទបងអរគុណច្រើនបង៕៕៕